Khmer

# United Nations Rules for the Treatment of Women Prisoners and Non-custodial Measures for Women Offenders

## (The Bangkok Rules)

*Unofficial Translation*

*By United Nations Human Rights Office of the High Commissioner, Cambodia*

# វិធានអង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី និងវិធានការ ដាក់ឲ្យនៅក្រៅការឃុំខ្លួនសម្រាប់ជនល្មើសជាស្ត្រី (វិធានបាងកក)

## អនុម័តដោយសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ (សេចក្តីសម្រេចលេខ A/RES/65/229)

---

### ការឃ្លាំមើលបឋម

១. លក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ[ក] អនុវត្តចំពោះគ្រប់ជនជាប់ឃុំទាំងអស់ដោយគ្មានការរើសអើង។ ដូច្នោះហើយ តម្រូវការជាក់លាក់ និងភាពពិតនៃជនជាប់ឃុំទាំងអស់ រួមបញ្ចូលទាំងជនជាប់ឃុំជាស្ត្រី គួរត្រូវបានយកមកពិចារណាក្នុងការអនុវត្តន៍នៃលក្ខខណ្ឌទាំងនោះ។ ទោះជាដូច្នោះក៏ដោយ វិធាននោះដែលត្រូវបានអនុម័តកាលពីជាង ៥០ឆ្នាំមុន ពុំបានទាក់ទាញការយកចិត្តទុកដាក់ គ្រប់គ្រាន់លើតម្រូវការពិសេសនានារបស់ស្ត្រីនោះទេ។ ដោយសារចំនួននៃជនជាប់ឃុំជាស្ត្រីនៅទូទាំងពិភពលោកកាន់តែកើនឡើង តម្រូវការឲ្យមានការពិនិត្យពិច័យឲ្យកាន់តែច្បាស់លាស់ឡើង ចំពោះប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី គឺជាកិច្ចការដ៏មានសារសំខាន់ និងបន្ទាន់មួយ។

២.ទទួលស្គាល់នូវតម្រូវការក្នុងការផ្តល់បទដ្ឋានសកលទាក់ទិននឹងការពិនិត្យពិច័យដាច់ដោយឡែកដែលគួរអនុវត្តចំពោះជនជាប់ឃុំ និងជនល្មើសជាស្ត្រី ព្រមទាំងយកមកពិចារណានូវដំណោះស្រាយពាក់ព័ន្ធដែលត្រូវបានអនុម័តដោយស្ថាប័ននានានៃអង្គការសហប្រជាជាតិ ដែលរដ្ឋជាសមាជិកនានា ត្រូវបានអំពាវនាវឲ្យឆ្លើយតបសមស្របទៅនឹងតម្រូវការនៃជនល្មើស ឬជនជាប់ឃុំជាស្ត្រី វិធានបច្ចុប្បន្ននេះ ត្រូវបានបង្កើតឡើងដើម្បីបង្គ្រប់ និងបំពេញតាមការគួរ នូវលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ និងលក្ខខណ្ឌបទដ្ឋានអប្បបរមាអង្គការសហប្រជាជាតិសម្រាប់វិធានការមិនដាក់ឲ្យជាប់ក្នុងការឃុំខ្លួន (វិធានតូក្យូ)[ខ] ទាក់ទិននឹងប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី និងជម្រើសផ្សេងៗ ក្រៅពីដាក់ជនល្មើសជាស្ត្រីក្នុងពន្ធនាគារ។

៣. វិធានថ្មីនេះពុំជំនួសឲ្យលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី ឬវិធានតូក្យូ ក្នុងបែបផែនណាមួយនោះឡើយ ហេតុដូច្នោះហើយ គ្រប់បទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់ដែលមាននៅក្នុងវិធានទាំងពីរនេះ នៅតែបន្តអនុវត្តចំពោះគ្រប់ជនជាប់ឃុំ និងជនល្មើសជាស្ត្រីទាំងអស់ ដោយពុំ

---

[ក] សិទ្ធិមនុស្ស៖ កម្រងលិខិតុបករណ៍អន្តរជាតិ/ ភាគទី១ ផ្នែកទី១៖ *លិខិតុបករណ៍សកលនានា (*បោះផ្សាយដោយអង្គការសហប្រជាជាតិ/ លក់លេខ E.02.XIV.4 (vol. I, Part I)) sect. J, No. 34។

[ខ] សេចក្តីសម្រេចចិត្តលេខ ៤៥/១១០ ឧបសម្ព័ន្ធ

[គ] សន្និបាតអង្គការសហប្រជាជាតិលើកទី៦ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តកម្មលើជនល្មើស នៅទីក្រុងការាកាស ថ្ងៃទី២៥ ខែសីហា ដល់ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៨០៖ របាយការណ៍ត្រូវបានរៀបចំដោយលេខាធិការដ្ឋាន (ការបោះផ្សាយរបស់អង្គការសហប្រជាជាតិ Sales No. E.81.IV.4) ជំពូកទី១ ប្រការ ខ សេចក្តីសម្រេចចិត្តលេខ៩ (ស្តីពីប្រព្រឹត្តកម្មសមរម្យចំពោះស្ត្រី ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ)។

មានការរើសអើង។ វិធានផ្សេងទៀតគ្របដណ្តប់លើវិស័យថ្មីៗទៀត ខណៈដែលវិធានថ្មីនេះនាំមកនូវភាពច្បាស់លាស់បន្ថែមទៀត សម្រាប់បទប្បញ្ញត្តិដែលមានស្រាប់នៅក្នុងលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ និងវិធានតូក្យូ ចំពោះការអនុវត្តន៍នៃវិធានទាំងនេះលើជនជាប់ឃុំ និងជនល្មើសជាស្ត្រី។

៤. វិធានទាំងនេះកើតចេញមកពីគោលការណ៍នានា ដែលមាននៅក្នុងអនុសញ្ញា និងសេចក្តីប្រកាសនានា របស់អង្គការសហប្រជាជាតិ ហេតុដូច្នោះហើយអនុលោមតាមបទបញ្ញត្តិ នៃច្បាប់អន្តរជាតិដែលមានស្រាប់។ វិធានទាំងនេះត្រូវបានលើកបង្ហាញដល់អាជ្ញាធរពន្ធនាគារ និងភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ (រួមមាន អ្នកបង្កើតគោលនយោបាយ សមាជិកសភា អយ្យការ តុលាការ និងសេវាព្យួរទោសមានលក្ខខណ្ឌ) ដែលពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងនៃទណ្ឌកម្ម ដាក់ស្ថិតក្រៅការឃុំខ្លួន និងវិធានការផ្អែកលើសហគមន៍នានា។

៥. លក្ខខណ្ឌតម្រូវជាក់លាក់នានាសម្រាប់ដោះស្រាយស្ថានភាពរបស់ជនល្មើសជាស្ត្រីត្រូវបានគូសបញ្ជាក់នៅឯអង្គការសហប្រជាជាតិនៅក្នុងបរិបទខុសៗគ្នា។ ឧទាហរណ៍ នៅក្នុងឆ្នាំ១៩៨០ សន្និបាតអង្គការសហប្រជាជាតិលើកទី៦ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តកម្មលើជនល្មើស បានអនុម័តសេចក្តីសម្រេចចិត្តមួយស្តីពីតម្រូវការជាក់លាក់នៃជនជាប់ឃុំជាស្ត្រី ដែលក្នុងនោះ វាបានផ្តល់អនុសាសន៍ថា នៅក្នុងការអនុវត្តន៍សេចក្តីសម្រេចចិត្តដែលត្រូវបានអនុម័តដោយ សន្និបាតលើកទី៦ ដែលពាក់ព័ន្ធដោយផ្ទាល់ ឬមិនផ្ទាល់ចំពោះប្រព្រឹត្តកម្មលើជនល្មើស ការទទួលស្គាល់គួរតែផ្តល់ទៅលើបញ្ហាជាក់លាក់នានារបស់ជនជាប់ឃុំជាស្ត្រី និងតម្រូវការក្នុងការផ្តល់មធ្យោបាយសម្រាប់ដំណោះស្រាយរបស់ពួកគេ និងថា នៅក្នុងប្រទេសដែលមិនទាន់បានធ្វើនៅឡើយ កម្មវិធី និងសេវាដែលត្រូវបានប្រើប្រាស់ជាជម្រើសផ្សេង ក្រៅពីការដាក់ពន្ធនាគារ គួរត្រូវបានយកមកប្រើប្រាស់ចំពោះជនល្មើសជាស្ត្រីនានា នៅលើមូលដ្ឋានស្មើភាពជាមួយនឹងជនល្មើសជាបុរសដែរ។ ចំណែកឯអង្គការសហប្រជាជាតិ អង្គការរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនានានៅក្នុងឋានៈជាអ្នកប្រឹក្សាយោបល់ ព្រមទាំងអង្គការអន្តរជាតិទាំងអស់គួរប្រឹងប្រែងបន្តទៀត ដើម្បីធានាថា ជនល្មើសជាស្ត្រីត្រូវគេប្រព្រឹត្តលើខ្លួនដោយយុត្តិធម៌ និងសមភាព នៅកំឡុងពេលនៃ ការឃាត់ខ្លួន ជំនុំជម្រះ ផ្តន្ទាទោស និងដាក់ពន្ធនាគារ ដោយឡែកគេត្រូវផ្តល់ការយកចិត្តទុកដាក់ ចំពោះបញ្ហាពិសេសនានា ដែលជនល្មើសជាស្ត្រីជួបប្រទះ ជាអាទិ៍ ការមានផ្ទៃពោះ និងការថែទាំកូន។[៣]

៦. សន្និបាតលើកទី៧[៤] សន្និបាតលើកទី៨[៥] សន្និបាតលើកទី៩[៦] ក៏បានផ្តល់អនុសាសន៍ ជាក់លាក់នានាផងដែរ ទាក់ទិននឹងជនជាប់ឃុំជាស្ត្រី។

៧. នៅក្នុងសេចក្តីប្រកាសទីក្រុងវីយ៉ែនស្តីពីបទល្មើស និងយុត្តិធម៌៖ ដោះស្រាយការប្រឈមនៃសតវត្សរ៍ទី២១[៧] ដែលត្រូវបានអនុម័តដោយសន្និបាតលើកទី៩នោះ រដ្ឋជាសមាជិកបានប្តេជ្ញាថា នឹងយកទៅពិចារណា និងស្វែងរកមធ្យោបាយដោះស្រាយនៅក្នុងកម្មវិធីបង្ការបទល្មើស និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌរបស់អង្គការសហប្រជាជាតិ ក៏ដូចជានៅក្នុងយុទ្ធសាស្រ្តបង្ការ បទល្មើស និងប្រព័ន្ធយុត្តិធម៌

ព្រហ្មទណ្ឌថ្នាក់ជាតិដែរ នូវការប៉ះពាល់ដែលមិនស៊ីសង្វាក់គ្នា ណាមួយនៃកម្មវិធី និងគោលនយោបាយនានាស្តីពីស្ត្រី និងបុរស វាក្យខណ្ឌទី១១) និងចំពោះការបង្កើតអនុសាសន៍គោលនយោបាយសំដៅលើការអនុវត្តន៍ដោយផ្អែកលើតម្រូវការពិសេសនានារបស់ជនជាប់ឃុំ និងជនល្មើសជាស្ត្រី (វាក្យខណ្ឌទី១២)។ គម្រោងសកម្មភាពសម្រាប់អនុវត្ត សេចក្តីប្រកាសវៀយ៉ែន[ជ] មានប្រការដោយឡែកមួយ (ប្រការ XIII) ដែល ផ្តោតទៅលើវិធានការ ផ្អែកតាមការផ្តល់អនុសាសន៍យ៉ាងជាក់លាក់ ដើម្បីតាមដានលើការប្តេជ្ញាដែលបាន កំណត់នៅក្នុង វាក្យខណ្ឌ១១ និង១២ នៃសេចក្តីថ្លែងការណ៍នេះ រួមបញ្ចូលទាំងការងារពិនិត្យឡើងវិញ របស់រដ្ឋ វាយតំលៃ និងប្រសិនបើចាំបាច់ ធ្វើការកែសម្រួលក្របខណ្ឌច្បាប់ គោលនយោបាយ នីតិវិធី និងការអនុវត្តន៍នានា ទាក់ទងនឹងបញ្ហាព្រហ្មទណ្ឌ ក្នុងលក្ខណៈមួយដែលស៊ីសង្វាក់គ្នានឹងប្រព័ន្ធច្បាប់របស់រដ្ឋទាំងនោះ ដើម្បីធានាថា ស្ត្រីត្រូវបានប្រព្រឹត្តលើខ្លួនយ៉ាងយុត្តិធម៌ ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។

៨. មហាសន្និបាត នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៥៨/១៨៣ ចុះថ្ងៃទិ២២ ខែធ្នូ ឆ្នាំ២០០៣ របស់ខ្លួន ដែលមានចំណងជើងថា "សិទ្ធិមនុស្សនៅក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌" បានអំពាវនាវ ឲ្យបង្កើនការយកចិត្តទុកដាក់ទៅលើបញ្ហារបស់ស្ត្រីនៅក្នុងពន្ធនាគារ ដោយរួមបញ្ចូលទាំងកូនរបស់ស្ត្រីនៅក្នុងពន្ធនាគារ ដោយប្រកាន់ខ្ជាប់នូវគំនិតក្នុងការកំណត់បញ្ហា និងមធ្យោបាយដែលអាចដោះស្រាយបញ្ហាទាំងនោះបាន។

៩. នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៦១/១៤៣ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ របស់ខ្លួនដែលមានចំណងជើងថា "បង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីបំបាត់រាល់ទម្រង់នៃអំពើហិង្សាប្រឆាំងស្ត្រី" មហាសន្និបាត បានគូសបញ្ជាក់ថា "អំពើហិង្សាប្រឆាំងស្ត្រី" មានន័យថាជាទង្វើណាមួយនៃ អំពើហិង្សា ខាងយ៉ែនឌ័រ ដែលបណ្តាលឲ្យ ឬទំនងជាបណ្តាលឲ្យមានព្យសនៈកម្ម ឬការឈឺចាប់ ខាងរូបរាងកាយ ខាងផ្លូវភេទ ឬខាងផ្លូវចិត្តចំពោះស្ត្រី ដែលរួមមានការដកហូតសេរីភាពតាមទំនើងចិត្ត ទោះបីជាអំពើនោះ កើតឡើងនៅ

---

[ឃ] *សន្និបាតអង្គការសហប្រជាជាតិលើកទី៧ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តកម្មលើជនល្មើស នៅទីក្រុងមីឡែន ថ្ងៃទី២៦ ខែសីហា ដល់ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៨៥៖ របាយការណ៍រៀបចំដោយលេខាធិការដ្ឋាន* (ការបោះផ្សាយរបស់អង្គការសហប្រជាជាតិ Sales No. E.86.IV.1) ជំពូកទី១ ប្រការ ង សេចក្តីសម្រេចចិត្តលេខ៦ (ស្តីពីប្រព្រឹត្តកម្មសមរម្យចំពោះស្ត្រី ដោយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ)។

[ង] គោលការណ៍ជាមូលដ្ឋានសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ (សេចក្តីសម្រេចចិត្តរបស់មហាសន្និបាត លេខ៤៥/១១១ ឧបសម្ព័ន្ធ)។ *សន្និបាតអង្គការសហប្រជាជាតិលើកទី៨ ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តកម្មលើជនល្មើស នៅទីក្រុងហាវាណា ថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០៖ របាយការណ៍រៀបចំដោយលេខាធិការដ្ឋាន* (ការបោះផ្សាយរបស់អង្គការសហប្រជាជាតិ Sales No. E.91.IV.2) ជំពូកទី១ ប្រការ គ សេចក្តីសម្រេចចិត្តលេខ១៧ (ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន) លេខ១៩ (ស្តីពីការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងការបង្កើតគោលនយោបាយផ្តន្ទាទោស) និងលេខ២១ (ស្តីពីសហប្រតិបត្តិការអន្តរជាតិ និងអន្តរតំបន់នៅក្នុងការគ្រប់គ្រងពន្ធនាគារ និងទណ្ឌកម្មបម្រើសហគមន៍ ព្រមទាំងបញ្ហាផ្សេងៗទៀត)។

[ច] A/CONF.169/16/Rev.1 ជំពូកទី១ សេចក្តីសម្រេចចិត្តលេខ១ (ស្តីពីអនុសាសន៍លើប្រធានបទសំខាន់ៗចំនួនបួនរបស់សន្និបាតអង្គការសហប្រជាជាតិលើកទី៩ស្តីពីការបង្ការបទល្មើស និងប្រព្រឹត្តកម្មលើជនល្មើស) លេខ៥ (ស្តីពីការអនុវត្តន៍ជាក់ស្តែងនៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ) និងលេខ៨ (ស្តីពីការបំបាត់អំពើហិង្សា ប្រឆាំងនឹងស្ត្រី)។

[ឆ] សេចក្តីសម្រេចចិត្តលេខ ៥៥/៥៩ ឧបសម្ព័ន្ធ។

[ជ] សេចក្តីសម្រេចចិត្តលេខ ៥៦/២៦១ ឧបសម្ព័ន្ធ។

ក្នុងជីវិតសាធារណៈ ឬឯកជនក្តី និងបានជំរុញឲ្យរដ្ឋនានាធ្វើការពិនិត្យឡើងវិញ និងតាមតែ អាចធ្វើទៅបាន កែប្រែ ឬលុបច្បាប់ បទបញ្ញត្តិ គោលនយោបាយ ការអនុវត្តន៍ និងទំនៀមទំលាប់ទាំងអស់ ដែលរើសអើងប្រឆាំងនឹងស្ត្រី ឬដែលមានផលប៉ះពាល់ដែលមានលក្ខណៈរើសអើងលើស្ត្រី ព្រមទាំងធានាថា បទបញ្ញត្តិនានានៃប្រព័ន្ធ ពហុគតិយុត្ត ប្រសិនបើមានអនុលោមតាមកាតព្វកិច្ច ការប្តេជ្ញា និងគោលការណ៍ សិទ្ធិមនុស្សអន្តរជាតិ ដែលរួមមានគោលការណ៍នៃការមិនរើសអើង ប្រកាន់យកវិធានការវិជ្ជមាន ដើម្បីស្វែងរកមូលហេតុជារចនាសម្ព័ន្ធនៃអំពើហិង្សាប្រឆាំងស្ត្រី និងដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែង បង្ការ ដោយដោះស្រាយនឹងការអនុវត្តន៍ដែលមានលក្ខណៈរើសអើង និងនិយាមសង្គម រួមបញ្ចូលទាំងស្ត្រី ដែលត្រូវការការយកចិត្តទុកដាក់ជាពិសេស ជាអាទិ៍ស្ត្រីស្ថិតក្នុងមណ្ឌលអប់រំកែប្រែ ឬក្នុងកន្លែងឃុំខ្លួន ព្រមទាំងផ្តល់ការបណ្តុះបណ្តាល និងកសាងសមត្ថភាព ស្តីពីសមភាពយេនឌ័រ និងសិទ្ធិស្ត្រី ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ។ សេចក្តីសម្រេចចិត្តនេះគឺជាការទទួលស្គាល់ថា អំពើហិង្សា ប្រឆាំងស្ត្រីមានភាពជំពាក់ជំពិនជាក់លាក់ចំពោះស្ត្រីដែលប្រឈមនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដូចជាសិទ្ធិរបស់ពួកគេក្នុងការរួចផុតពីការធ្លាក់ខ្លួនជាជនរងគ្រោះនៅកំឡុងពេលជាប់ឃុំខ្លួន។ វិធាននេះផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើសុវត្ថិភាពខាងរូបវន្ត និងផ្លូវចិត្តរបស់ជនជាប់ឃុំជាស្ត្រី ព្រោះវាមានសារសំខាន់ ដើម្បីធានាដល់ការគោរពសិទ្ធិមនុស្ស និងការស្តារនីតិសម្បទារបស់ពួកគេ។

១០. ជាទីបញ្ចប់ សេចក្តីប្រកាសបាងកកស្តីពីកិច្ចសហការណ៍គ្នា និងការឆ្លើយតបៈ សម្ព័ន្ធជាយុទ្ធសាស្ត្រនៅក្នុងការបង្ការបទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ[ឈ] ដែលត្រូវបានអនុម័តដោយ សន្និបាតអង្គការសហប្រជាជាតិលើកទី៧ស្តីពីការបង្ការបទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៥ ដោយរដ្ឋជាសមាជិកបានប្រកាសថា ពួកគេប្តេជ្ញាបង្កើត និងរក្សាស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌឲ្យមានយុត្តិធម៌ និងប្រសិទ្ធិភាព រួមបញ្ចូលទាំងការប្រព្រឹត្តដោយមនុស្សធម៌ នៅគ្រប់កន្លែងឃុំខ្លួនបណ្តោះអាសន្ន និងមណ្ឌលអប់រំកែប្រែទាំងអស់ ដោយអនុលោមតាមបទដ្ឋានអន្តរជាតិជាធរមាននានា (វាក្យខណ្ឌទី៨) ហើយរដ្ឋទាំងនោះបានផ្តល់អនុសាសន៍ថា គណៈកម្មការស្តីពីការបង្ការបទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ គួរពិចារណាទៅលើការពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃបទដ្ឋានគតិយុត្តិនានា ដែលទាក់ទិននឹងការគ្រប់គ្រងពន្ធនាគារ និងជនជាប់ឃុំ (វាក្យខណ្ឌទី ៣០)។

១១. ដូចគ្នានឹងវិធានបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំដែរ ដោយសារភាពខុសគ្នាដ៏ធំធេងនៃលក្ខខណ្ឌច្បាប់ សង្គម សេដ្ឋកិច្ច និងភូមិសាស្ត្រ នៅទូទាំងពិភពលោក មានភស្តុតាង បង្ហាញថា មិនមែនគ្រប់វិធានខាងក្រោមទាំងអស់សុទ្ធតែអាចយកទៅអនុវត្តឲ្យស្មើគ្នានៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងអស់នោះទេ។ ទោះជាដូច្នោះក៏ដោយ វិធានទាំងនោះគួរប្រើប្រាស់ ដើម្បីជំរុញដល់កិច្ចខិតខំប្រឹងប្រែងជាបន្ត ដើម្បីយកឈ្នះលើការលំបាកជាក់ស្តែងនានា នៅក្នុងរបៀបអនុវត្តន៍វិធានទាំងនោះ ដោយយល់ថា វិធានទាំងនោះតំណាងទាំងស្រុងនូវការប្រាថ្នាចង់បានជាសកល ដែលអង្គការសហប្រជាជាតិចាត់

[ឈ] សេចក្តីសម្រេចចិត្តលេខ ៦០/១៧៧ ឧបសម្ព័ន្ធ

ទុកថាជាគោលដៅរួម នាំមុខគេនៃការធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពរបស់ជនជាប់ឃុំជាស្ត្រី កូនៗ និងសហគមន៍របស់ពួកគេ។

១២. ភាគខ្លះនៃវិធានទាំងនោះលើកឡើងនូវបញ្ហានានា ដែលអាចអនុវត្តបានទាំងចំពោះជនជាប់ឃុំជាបុរស និងស្ត្រី រួមបញ្ចូលទាំងវិធានមួយចំនួនដែលទាក់ទងនឹងការទទួលខុសត្រូវរបស់ឪពុកម្តាយ សេវាសុខភាពមួយចំនួន នីតិវិធីឆែកឆេរ និងនីតិវិធីផ្សេងៗទៀតដែលស្រដៀងគ្នានេះ ទោះបីជាវិធានទាំងនោះយកចិត្តទុកដាក់ជាចម្បងទៅលើតម្រូវការរបស់ស្ត្រី និងកូនៗរបស់ពួកគេក៏ដោយ។ ទោះបីជាយ៉ាងក៏ដោយ ដោយសារការយកចិត្តទុកដាក់រួមបញ្ចូលកូនៗរបស់ស្ត្រីជាប់ឃុំខ្លួន ដូច្នោះត្រូវការឲ្យមានការទទួលស្គាល់នូវតួនាទីស្នូលរបស់ឪពុកម្តាយនៅជីវិតកូនៗរបស់ពួកគេ។ អាស្រ័យហេតុនេះ ភាគខ្លះនៃវិធានទាំងនេះនឹងត្រូវអនុវត្តស្មើគ្នាចំពោះជនជាប់ឃុំជាបុរស និងជនល្មើសដែលជាឪពុកនានា។

**សេចក្តីផ្តើម**

១៣. វិធានខាងក្រោមទាំងនេះពុំជំនួសឲ្យលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ និងវិធានតូក្យូក្នុងបែបផែនណាមួយឡើយ។ ដូច្នោះហើយ បទបញ្ញត្តិទាំងអស់ដែលមានចែងនៅក្នុងវិធានទាំងពីរនេះ ត្រូវបន្តអនុវត្តចំពោះគ្រប់ជនជាប់ឃុំ និងជនល្មើសទាំងអស់ដោយគ្មានការរើសអើងឡើយ។

១៤. ផ្នែកទី១នៃវិធានបច្ចុប្បន្ននេះ ដែលគ្របដណ្តប់លើការគ្រប់គ្រងទូទៅនៃស្ថាប័ននានាអាចយកទៅអនុវត្តបានចំពោះស្ត្រីគ្រប់ចំណាត់ថ្នាក់ទាំងអស់ ដែលសេរីភាពរបស់ពួកគេត្រូវបានគេដកហូត រួមបញ្ចូលទាំងស្ត្រីជាប់ចោទពីបទព្រហ្មទណ្ឌ ឬស៊ីវិល មិនទាន់ជំនុំជម្រះ ឬផ្តន្ទាទោសរួមហើយ ក៏ដូចជាស្ត្រីដែលត្រូវដាក់ឲ្យស្ថិតក្រោម "វិធានការសន្តិសុខ" ឬវិធានការកែប្រែ ដែលត្រូវបានបង្គាប់ដោយតុលាការ។

១៥. ផ្នែកទី២ មានចែងពីវិធាននានាដែលអាចអនុវត្តបានចំពោះតែចំណាត់ថ្នាក់ពិសេស ដែលដោះស្រាយចំពោះអនុផ្នែកនិមួយៗប៉ុណ្ណោះ។ ទោះជាយ៉ាងដូច្នោះក៏ដោយ វិធានក្រោម អនុផ្នែក ក ដែលអាចអនុវត្តបានចំពោះជនជាប់ឃុំ ត្រូវតែអនុវត្តបានស្មើគ្នានឹងក្រុមជនជាប់ឃុំ នៅក្រោមអនុផ្នែក ខ ដោយសារតែ ពួកគេពុំមានវិវាទនឹងវិធាននានាដែលគ្រប់គ្រងខាងស្ត្រី ហើយសម្រាប់ផលប្រយោជន៍របស់ពួកគេ។

១៦. អនុផ្នែក ក និង ខ សុទ្ធតែចែងអំពីវិធានសម្រាប់ប្រព្រឹត្តកម្មលើស្ត្រីជាប់ឃុំ ដែលជាអនីតិជន។ ទោះជាដូច្នោះក៏ដោយ ជាការសំខាន់ដែលត្រូវកត់សំគាល់ថា យុទ្ធសាស្ត្រ និងគោលនយោបាយដាច់ដោយឡែកនានា ដែលអនុលោមតាមបទដ្ឋានអន្តរជាតិនានា ជាពិសេស លក្ខខណ្ឌបទដ្ឋានអប្បបរមារបស់អង្គការសហប្រជាជាតិ សម្រាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ អនីតិជន (វិធានប៉េកាំង)[៣] សេចក្តីណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ការបង្ការបទល្មើស អនីតិជន (សេចក្តីណែនាំរីយ៉ាដហ៍)[៤] វិធានអង្គការសហប្រជាជាតិ

---

[៣] សេចក្តីសម្រេចចិត្តលេខ ៤០/៣៣ ឧបសម្ព័ន្ធ

[៤] សេចក្តីសម្រេចចិត្តលេខ ៤៥/១១២ ឧបសម្ព័ន្ធ

សម្រាប់ការពារអនីតិជន ដែលត្រូវបានដកហូតសេរីភាព[ឋ] និងសេចក្ដីណែនាំសម្រាប់សកម្មភាពលើកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[ឌ] ត្រូវការបង្កើតឡើងដើម្បីសម្រាប់ប្រព្រឹត្តកម្ម និងស្ដារនីតិសម្បទានរបស់ជនជាប់ឃុំ នានាដែលស្ថិតក្នុងជំពូកនេះ ខណៈដែលស្ថាប័នុបណីវកម្មត្រូវតែជៀសវាងជាអតិបរមា តាមតែអាចធ្វើទៅរួច។

១៧. ផ្នែកទី៣ ចែងអំពីវិធានដែលគ្របដណ្ដប់លើការអនុវត្តន៍នៃទណ្ឌកម្ម និងវិធានការមិនដាក់ឲ្យជាប់ឃុំសម្រាប់ជនជាប់ឃុំជាស្ត្រី និងអនីតិជនជាកុមារី រួមបញ្ចូលទាំងការឃាត់ខ្លួន និងដំណាក់កាលមុនជំនុំជម្រះ ពេលជំនុំជម្រះ និងក្រោយជំនុំជម្រះនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

១៨. ផ្នែកទី៤ ចែងអំពីវិធានស្ដីពីការស្រាវជ្រាវ ការរៀបចំផែនការ ការវាយតំលៃ ការលើកកំពស់ការយល់ដឹងជាសាធារណៈ និងការចែករំលែកព័ត៌មាន ហើយអនុវត្តបានចំពោះគ្រប់ចំណាត់ថ្នាក់ នៃជនជាប់ឃុំជាស្ត្រី ដែលត្រូវបានគ្របដណ្ដប់នៅក្នុងវិធានទាំងនេះ។

## I . វិធាននានានៃការអនុវត្តន៍ទូទៅ

## ១. គោលការណ៍មូលដ្ឋាន

(វិធានអនុវត្តន៍ទី៦នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ)

វិធាន១

ដើម្បីឲ្យគោលការណ៍មិនរើសអើង ដែលចែងក្នុងវិធាន៦នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំត្រូវយកទៅអនុវត្តបាន គេត្រូវពិចារណាទៅលើតម្រូវការជាច់ដោយឡែករបស់ជនជាប់ឃុំជាស្ត្រីនៅក្នុងការអនុវត្តន៍វិធានទាំងនេះ។ ការផ្ដល់ឲ្យសម្រាប់តម្រូវការបែបទាំងនេះ ដើម្បីសម្រេចបាននូវសមភាពយ៉េនឌ័រជាសារវន្តមិនត្រូវចាត់ទុកថាជាអំពើរើសអើងនោះទេ។

## ២. ការទទួលយកជនជាប់ឃុំ

*វិធាន២*

១. ត្រូវផ្ដល់ការយកចិត្តទុកដាក់គ្រប់គ្រាន់ដល់នីតិវិធីទទួលយកសម្រាប់ជនជាប់ឃុំជាស្ត្រី និងកុមារ ដោយសារតែភាពងាយរងគ្រោះជាដោយឡែករបស់ពួកគេនាពេលបច្ចុប្បន្ន។ ជនជាប់ឃុំជាស្ត្រី ដែលទើបមកដល់ថ្មី ត្រូវទទួលបានមធ្យោបាយដើម្បីទំនាក់ទំនងសាច់ញាតិរបស់ពួកគេ ប្រឹក្សាផ្នែកច្បាប់ ព័ត៌មានអំពីវិធាន និងបទបញ្ញត្តិ ពន្ធនាគារ របៀបរបបពន្ធនាគារ និងកន្លែងដើម្បីស្វែងរកជំនួយដោយប្រើប្រាស់ភាសាដែល

---

[ឋ] សេចក្ដីសម្រេចចិត្តលេខ ៤៥/១១៣ ឧបសម្ព័ន្ធ

[ឌ] សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច លេខ១៩៩៧/៣០ឧបសម្ព័ន្ធ

ពួកគេចេះ និងក្នុងករណីដែលជនជាប់ឃុំជាជនបរទេស ពួកគេត្រូវមានសិទ្ធិធ្វើទំនាក់ទំនងនឹងតំណាងកុងស៊ុលផងដែរ។

២. មុនពេល ឬពេលទទួលបានការអនុញ្ញាត ស្ត្រីដែលមានទំនួលខុសត្រូវថែរក្សាកូនត្រូវទទួលបានការអនុញ្ញាតឲ្យធ្វើការចាត់ចែងសម្រាប់កូនរបស់ពួកគេ រួមបញ្ចូលទាំងការពន្យាពេលឃុំខ្លួនក្នុងរយៈពេលសមស្របមួយ ដោយពិចារណាខ្ពស់អំពីផលប្រយោជន៍របស់កុមារ។

**៣. ការចុះបញ្ជី**

[វិធានលេខ៧ នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ]

*វិធាន៣*

១. ចំនួន និងសវាតាលំអិតរបស់កូនដែលម្ដាយកំពុងត្រូវបានទទួលចូលពន្ធនាគារ ត្រូវធ្វើការកត់ត្រានៅពេលនៃការទទួលចូលពន្ធនាគារនោះ។ ដោយពុំបុរេវិនិច្ឆ័យសិទ្ធិនានារបស់ម្ដាយ កំណត់ត្រានោះ ត្រូវរួមបញ្ចូលយ៉ាងហោចណាស់នូវឈ្មោះរបស់កុមារ អាយុរបស់ពួកគេ ហើយប្រសិនបើ ពួកគេពុំមកតាមម្ដាយរបស់ពួកគេទេនោះ ត្រូវកត់ត្រាទីកន្លែង និងស្ថានភាពនៃអ្នកគ្រប់គ្រង ឬអាណាព្យាបាលស្របច្បាប់របស់ពួកគេ។

២. រាល់ព័ត៌មានទាំងអស់ ដែលទាក់ទងនឹងអត្តសញ្ញាណរបស់កុមារ ត្រូវរក្សាជាការសម្ងាត់ ហើយរាល់ការប្រើប្រាស់នៃព័ត៌មានទាំងអស់នោះជានិច្ចកាលត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវ ដោយត្រូវគិតគូខ្ពស់អំពីផលប្រយោជន៍របស់ពួកគេ។

**៤. ការបញ្ជូន ឬផ្ទេរខ្លួន**

*វិធាន៤*

ជនជាប់ឃុំជាស្ត្រីត្រូវឃុំ ឬបញ្ជូនខ្លួនទៅកាន់ពន្ធនាគារនានា ដែលនៅជិតនឹងលំនៅដ្ឋាន ឬមណ្ឌលស្តារនីតិសម្បទានសង្គមកិច្ច ដោយពិចារណាទៅលើទំនួលខុសត្រូវថែរក្សាកូនរបស់ពួកគេ ក៏ដូចជាចំណូលចិត្ត និងការទទួលបានកម្មវិធី និងសេវាសមស្របរបស់ស្ត្រីរៀងៗខ្លួន។

**៥. អនាម័យផ្ទាល់ខ្លួន**

*[ វិធានបន្ថែមទី១៥ និង១៦ នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ]*

*វិធាន៥*

កន្លែងឃុំខ្លួនជនជាប់ឃុំជាស្ត្រី ត្រូវមានឧបករណ៍ និងសម្ភារៈ ដែលតម្រូវឲ្យមានដើម្បីបំពេញតាមតម្រូវការខាងអនាម័យជាក់លាក់នានារបស់ស្ត្រី រួមមានកន្សែងអនាម័យ ដែលត្រូវចែកជូនដោយឥតគិតថ្លៃ និងការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់បម្រើការដល់ការថែរក្សារាងកាយកុមារ និងស្ត្រី ជាពិសេសស្ត្រីដែលពាក់ព័ន្ធនឹងការងារចំអិនអាហារ និងក្រុមស្ត្រីកំពុងមានផ្ទៃពោះ បំបៅដោះកូន ឬពេលមានរដូវ។

**៦. សេវាសុខាភិបាល**

*[ វិធានបំពេញទី ២២ ដល់២៦ នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្ម លើជនជាប់ឃុំ]*

(ក) **ការត្រួតពិនិត្យសុខភាពពេលចូលពន្ធនាគារ**

*[ វិធានបំពេញទី ២៤ នៃលក្ខខណ្ឌបទដ្ឋានអប្បបរមាសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំ]*

*វិធាន៦*

ការពិនិត្យសុខភាពរបស់ជនជាប់ឃុំជាស្ត្រីត្រូវរួមបញ្ចូលនូវការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដើម្បីកំណត់ពីតម្រូវការថែទាំសុខភាពបឋម និងត្រូវកំណត់ផងដែរនូវៈ

(ក) វត្តមាននៃជំងឺឆ្លងកាមរោគ ឬជំងឺឆ្លងតាមឈាម និងតាមកត្តាហានិភ័យនានា ជនជាប់ឃុំជាស្ត្រីក៏អាចទទួលបានការពិនិត្យមេរោគ HIV ផងដែរ ដោយមានការប្រឹក្សាទាំងមុន និងក្រោយពេលធ្វើការពិនិត្យ

(ខ) តម្រូវការថែទាំសុខភាពផ្លូវចិត្ត រួមបញ្ចូលទាំង ជំងឺផ្លូវចិត្តក្រោយជួបវិបត្តិធ្ងន់ធ្ងរ (post-traumatic stress disorder) និងហានិភ័យនៃការធ្វើអត្តឃាត និងការបង្ករគ្រោះថ្នាក់ដល់ខ្លួនឯង

(គ) ប្រវត្តិសុខភាពបន្តពូជរបស់ជនជាប់ឃុំជាស្ត្រី រួមមាន ការមានផ្ទៃពោះ ការសំរាលកូន និងបញ្ហាដែលទាក់ទងនឹងសុខភាពបន្តពូជ នាពេលបច្ចុប្បន្ន ឬថ្មីៗ

(ឃ) អាត្តិភាពនៃការពឹងអាស្រ័យលើសារធាតុញៀន

(ង) ការរំលោភបំពានខាងផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនៃអំពើហិង្សា ដែលអាចកើតឡើងមុនពេលចូលពន្ធនាគារ។

*វិធាន៧*

១. ប្រសិនបើអាត្តិភាពនៃការរំលោភបំពានខាងផ្លូវភេទ ឬទម្រង់ផ្សេងៗទៀតនៃអំពើហិង្សា មុនពេល ឬកំឡុងពេលនៃការឃុំខ្លួនត្រូវបានត្រួតពិនិត្យ ជនជាប់ឃុំជាស្ត្រីត្រូវទទួលបានការជូនដំណឹងអំពីសិទ្ធិរបស់គាត់ក្នុងការស្វែងរកឧបាស្រ័យពីអាជ្ញាធរតុលាការ។ ជនជាប់ឃុំជាស្ត្រីគួរត្រូវបានផ្តល់ព័ត៌មានយ៉ាងពេញលេញអំពីនីតិវិធី និងដំណាក់កាលដែលពាក់ព័ន្ធ។ ប្រសិនបើជនជាប់ឃុំជាស្ត្រីយល់ព្រមឲ្យចាត់វិធានការច្បាប់ គេត្រូវជូនដំណឹងនេះដល់មន្ត្រីពាក់ព័ន្ធ ហើយភ្លាមៗបញ្ជូនករណីនោះទៅដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីបើកការស៊ើបអង្កេត។ អាជ្ញាធរពន្ធនាគារនានាត្រូវជួយស្ត្រីបែបទាំងនោះ ឲ្យទទួលបានជំនួយផ្នែកច្បាប់។

២. ទោះបីជាស្ត្រីនោះជ្រើស ឬមិនជ្រើសក្នុងការចាត់វិធានការច្បាប់ អាជ្ញាធរពន្ធនាគារត្រូវខិតខំដើម្បីធានាថាស្ត្រីនោះទទួលបានភ្លាមៗនូវការគាំទ្រ ឬការប្រឹក្សាខាងចិត្តសាស្ត្រតាមបែបវិជ្ជាជីវៈ។

៣. គេត្រូវបង្កើតវិធានការជាក់លាក់នានាឡើង ដើម្បីបញ្ចៀសទម្រង់ណាមួយនៃការសងសឹកប្រឆាំងនឹងក្រុមបុគ្គលនានា ដែលផ្តល់សេចក្តីរាយការណ៍បែបនោះ ឬចាត់វិធានការច្បាប់។

*វិធាន៨*

គេត្រូវគោរពគ្រប់ពេលវេលាទាំងអស់នូវ សិទ្ធិរបស់ជនជាប់ឃុំជាស្ត្រីក្នុងការទទួលបានការសម្ងាត់ខាងវេជ្ជសាស្ត្រជាក់លាក់ រួមមានសិទ្ធិមិនឲ្យផ្សព្វផ្សាយព័ត៌មាន និងមិនឲ្យត្រួតពិនិត្យទាក់ទិននឹងប្រវត្តិសុខភាពបន្តពូជរបស់ពួកគេ។

*វិធាន៩*

ប្រសិនបើជនជាប់ឃុំជាស្ត្រីមានកូនរស់នៅជាមួយ កូននោះក៏ត្រូវទទួលការត្រួតពិនិត្យសុខភាពផងដែរ បើអាចធ្វើទៅបាននោះគឺត្រូវពិនិត្យដោយគ្រូពេទ្យជំនាញខាងសុខភាពកុមារ ដើម្បីកំណត់អំពីការព្យាបាល និងតម្រូវការខាងវេជ្ជសាស្ត្រនានា។ ត្រូវផ្តល់ឲ្យសេវាសុខភាពសមស្រប យ៉ាងហោចណាស់សមាមាត្រទៅនឹងសេវាក្នុងសហគមន៍។

**(ខ) សុខមាលភាពយេនឌ័រជាក់លាក់**

*វិធាន១០*

១. សេវាកម្មសុខមាលភាពយ៉េនឌ័រជាក់លាក់នានា យ៉ាងហោចណាស់ស្មើគ្នានឹងសេវាក្នុងសហគមន៍ត្រូវផ្ដល់ឲ្យជនជាប់ឃុំជាស្ត្រី។

២. ប្រសិនបើជនជាប់ឃុំជាស្ត្រីស្នើសុំទទួលការពិនិត្យជម្ងឺ ឬព្យាបាលដោយគ្រូពេទ្យ ឬគិលានុបដ្ឋាយិការជាស្ត្រី គេត្រូវប្រើឲ្យអស់លទ្ធភាពធ្វើទៅបាន ដើម្បីផ្ដល់គ្រូពេទ្យ ឬគិលានុបដ្ឋាយិការជាស្ត្រីតាមការស្នើសុំ លើកលែងតែក្នុងស្ថានភាពដែលតម្រូវឲ្យមានអន្តរាគមខាងវេជ្ជសាស្ត្រជាបន្ទាន់។ ប្រសិនបើគ្រូពេទ្យជាបុរស ធ្វើការពិនិត្យសុខភាពផ្ទុយនឹងការប្រាថ្នារបស់ជនជាប់ឃុំជាស្ត្រីនោះ បុគ្គលិកភេទស្រីម្នាក់ត្រូវមានវត្តមាននៅកំឡុងពេលនៃការពិនិត្យសុខភាពនោះ។

*វិធាន១១*

១. មានតែបុគ្គលិកពេទ្យប៉ុណ្ណោះដែលត្រូវមានវត្តមាននៅកំឡុងពេលពិនិត្យសុខភាព លុះត្រាតែវេជ្ជបណ្ឌិតនោះយល់ឃើញថា ជាកាលៈទេសៈពិសេស ឬវេជ្ជបណ្ឌិតនោះស្នើសុំឲ្យបុគ្គលិកពន្ធនាគារម្នាក់មានវត្តមានសម្រាប់ហេតុផលសន្តិសុខ ឬជនជាប់ឃុំជាស្ត្រីនោះស្នើសុំយ៉ាងជាក់លាក់ឲ្យមានវត្តមានបុគ្គលិកពន្ធនាគារ ដូចដែលបានបញ្ជាក់នៅក្នុងវិធាន១០ វាក្យខ័ណ្ឌ២ ខាងលើ។

២. ប្រសិនបើវាចាំបាច់ត្រូវឲ្យមានវត្តមានរបស់បុគ្គលិកពន្ធនាគារដែលមិនមែនជាបុគ្គលិកពេទ្យនៅកំឡុងពេលនៃការពិនិត្យសុខភាពនោះ បុគ្គលិកបែបនោះគួរតែជាស្ត្រី ហើយការពិនត្យនោះត្រូវធ្វើឡើងក្នុងលក្ខណៈ ដែលរក្សាការពារភាពឯកជន សេចក្តីថ្លៃថ្នូរ និងការសម្ងាត់របស់អ្នកជម្ងឺ។

**(គ) សុខភាពផ្លូវចិត្ត និងការគាំពារ**

*វិធាន១២*

គេត្រូវផ្តល់កម្មវិធីគាំពារ និងស្តារនីតិសម្បទាសុខភាពផ្លូវចិត្តក្នុងន័យឯកត្តបុគ្គល វេទយិតយ៉េនឌ័រដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត និងទូលំទូលាយ ឲ្យដល់ជនជាប់ឃុំជាស្ត្រីជាមួយនឹងត្រូវការគាំពារសុខភាពផ្លូវចិត្តនៅក្នុងពន្ធនាគារ ឬនៅក្នុងក្របខណ្ឌដាក់ឲ្យនៅក្រៅឃុំ។

*វិធាន១៣*

បុគ្គលិកពន្ធនាគារត្រូវយល់ដឹងអំពីពេលវេលា ដែលស្ត្រីអាចទទួលអារម្មណ៍ទុក្ខសោកជាពិសេស ដើម្បីងាយស្រួលកត់សំគាល់ស្ថានភាពរបស់ស្ត្រីទាំងនោះ និងធានាថាស្ត្រីទាំងនោះទទួលបានការគាំទ្រសមស្រប។

### (ឃ) ការបង្ការមេរោគអេដស៍/ជម្ងឺអេដស៍ ការព្យាបាល ការថែទាំ និង កិច្ចគាំពារ

*វិធាន ១៤*

ដើម្បីឲ្យមានការឆ្លើយតបចំពោះមេរោគអេដស៍/ជម្ងឺអេដស៍ នៅក្នុងស្ថាប័នព្រហ្មទណ្ឌ កម្មវិធី និងសេវាផ្សេងៗ ត្រូវតែបំពេញតាមសេចក្ដីត្រូវការជាក់លាក់របស់ស្ត្រីរាប់ទាំងការបង្ការការឆ្លងជម្ងឺពីម្ដាយទៅកូន។ ក្នុងបរិបទនេះ អាជ្ញាធរពន្ធនាគារត្រូវជំរុញលើកទឹកចិត្ត និងគាំទ្រដល់ការ បង្កើតគំនិតផ្ដួចផ្ដើមផ្សេងៗ ស្ដីពីការបង្ការមេរោគអេដស៍/ជម្ងឺអេដស៍ ការព្យាបាល ការថែទាំ ក៏ដូច ជាការអប់រំដល់ដៃគូ ។

### (ង) កម្មវិធីព្យាបាលសារធាតុញៀន

*វិធាន ១៥*

សេវាសុខភាពក្នុងពន្ធនាគារត្រូវផ្ដល់ ឬ សម្រួលកម្មវិធីព្យាបាលផ្នែកឯកទេស ដែលបានរៀបចំឡើងសំរាប់ជនជាប់ឃុំស្ត្រីដែលប្រើប្រាស់សារធាតុញៀន ដោយគិតគូរអំពីស្ថានភាពរបស់គាត់នៅមុនពេលក្លាយជាជនរងគ្រោះ សេចក្ដីត្រូវការជាពិសេសរបស់ស្ត្រីមានគត៌ និងស្ត្រីមានកូនតូច ក៏ដូចជាសវតាវប្បធម៌ចំរុះរបស់ពួកគាត់ ។

### (ច) ការបង្ការការធ្វើអត្តឃាត និង ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង

*វិធាន ១៦*

បង្កើត និង អនុវត្តយុទ្ធសាស្ត្រផ្សេងៗ ដោយពិគ្រោះយោបល់ជាមួយសេវាគាំពារសុខភាព ផ្លូវចិត្ត និងសេវាសុខមាលភាពសង្គម ដើម្បីបង្ការការធ្វើអត្តឃាត និងការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ក្នុងចំណោមជនជាប់ឃុំស្ត្រី និងផ្ដល់កិច្ចគាំទ្រផ្នែកឯកទេសសមស្រប និងជាក់លាក់ខាងយេនឌ័រ ដល់ជនជាប់ឃុំស្ត្រីទាំងឡាយដែលប្រឈមនឹងហានិភ័យ គឺជាផ្នែកមួយនៃគោលនយោបាយទូទៅ ស្ដីពីកិច្ចគាំពារសុខភាពផ្លូវចិត្តនៅក្នុងពន្ធនាគារជនជាប់ឃុំ។

**( ឆ ) សេវាបង្ការគាំពារសុខភាព**

*វិធាន ១៧*

ជនជាប់ឃុំស្រ្តី ត្រូវទទួលបានការអប់រំ និងព័ត៌មានអំពីវិធានការបង្ការគាំពារសុខភាព រាប់ទាំងមេរោគអេដស៍/ជម្ងឺអេដស៍ ជម្ងឺឆ្លងតាមរយៈការរួមភេទ ជម្ងឺឱកាសនិយមផ្សេងទៀត ព្រមទាំងអំពីលក្ខខណ្ឌផ្សេងៗ ទាក់ទងនឹងសុខភាពជាក់លាក់ខាងយ៉េនឌ័រ ។

*វិធាន ១៨*

វិធានការបង្ការថែទាំសុខភាព ទាក់ទងជាពិសេសដល់ស្រ្តី ដូចជាការធ្វើតេស៍មើលជម្ងឺមហារីកដោយយកកោសិកានៅកស្បូនមកធ្វើវិភាគ និងពិនិត្យមើលជម្ងឺមហារីកសុដន និងរោគស្រ្តីផ្សេងទៀត ត្រូវផ្តល់ឲ្យជនជាប់ឃុំស្រ្តីដោយស្មើភាពគ្នានឹងស្រ្តីដទៃទៀត ដែលមានវ័យប្រហាក់ប្រហែលគ្នានៅក្នុងសហគមន៍ផងដែរ។

**៧. សន្តិសុខ និង សុវត្ថិភាព**

*[ វិធាន ២៧ -៣៦ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

**ក. ការឆែកឆេរ**

*វិធាន ១៩*

ត្រូវចាត់វិធានការមានប្រសិទ្ធិភាព ដើម្បីធានាការពារ ការគោរព និងសេចក្តីថ្លៃថ្នូររបស់ជនជាប់ឃុំស្រ្តីនៅក្នុងអំឡុងពេលធ្វើការឆែកឆេរលើរាងកាយ ដែលមានតែបុគ្គលិកស្រ្តីទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវអំពីរបៀបឆែកឆេរប៉ុណ្ណោះ ទើបអាចធ្វើកិច្ចការនេះបាន ហើយត្រូវអនុវត្តតាមនីតិវិធីដែលបានកំណត់។

*វិធាន ២០*

វិធីសាស្រ្តពិនិត្យផ្សេងទៀត មានជាអាទិ៍ ការស្កេន ត្រូវបានបង្កើតឡើងជំនួសការពិនិត្យ ដោយដោះសំលៀកបំពាក់ និងការពិនិត្យដោយការឆែកឆេរលើរាងកាយ ដើម្បីជៀសវាងផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្ត ដែលបណ្តាលមកពីការឆែកឆេរលើរាងកាយ ។

*វិធាន ២១*

បុគ្គលិកពន្ធនាគារត្រូវបង្ហាញសមត្ថភាព វិជ្ជាជីវៈ និងការគិតគូរ ហើយត្រូវរក្សាការគោរព និងសេចក្តីថ្លៃថ្នូរ នៅពេលធ្វើការឆែកឆេរទាំងកូនដែលនៅក្នុងពន្ធនាគារជាមួយម្តាយ ទាំងកូនដែលមកសួរសុខម្តាយ ។

**ខ. វិន័យ និង ការដាក់ទោសទណ្ឌ**

*[ វិធានលេខ ២៧- ៣២ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ២២*

ការដាក់ទោសទណ្ឌដោយបង្ខាំង ឬដាក់បំបែកជាការវិន័យ មិនត្រូវបានអនុវត្តចំពោះស្ត្រីមាន ផ្ទៃពោះ ស្ត្រីមានទារក និងម្តាយដែលបំបៅកូនដោយទឹកដោះក្នុងពន្ធនាគារឡើយ ។

*វិធាន ២៣*

ការដាក់ទោសទណ្ឌខាងវិន័យចំពោះស្ត្រីជាប់ពន្ធនាគារ មិនត្រូវរាប់បញ្ចូលការហាមប្រាមណាមួយ មិនឲ្យប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារឡើយ ជាពិសេសជាមួយកូន ។

**គ. ឧបករណ៍សំរាប់ឃាឃាំងរាងកាយ**

*[ វិធានបំពេញលេខ ៣៣- ៣៤ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស]*

*វិធាន ២៤*

ឧបករណ៍សំរាប់ឃាឃាំងរាងកាយ មិនត្រូវបានប្រើប្រាស់ទៅលើជនជាប់ឃុំជាស្ត្រីនៅក្នុងពេលធ្វើការងារ ក្នុងពេលសម្រាលកូន និងបន្ទាប់ពីសម្រាលកូនភ្លាមឡើយ។

**ឃ. ព័ត៌មាន សំរាប់/និង ការតវ៉ាពីសំណាក់ជនជាប់ឃុំ - ការធ្វើអធិការកិច្ច**

*[ វិធានបំពេញលេខ ៣៥ និង៣៦ និងទាក់ទងនឹងការត្រួតពិនិត្យ វិធាន ៥៥ នៃបទបញ្ញត្តិជាបទដ្ឋាន អប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ២៥*

១. ជនជាប់ឃុំស្ត្រីដែលរាយការណ៍អំពីការរំលោភបំពាន ត្រូវផ្តល់កិច្ចការពារ ការគាំទ្រ និងការប្រឹក្សាយោបល់ ហើយការទាមទាររបស់ពួកគេត្រូវតែបានធ្វើការស៊ើបអង្កេតដោយអាជ្ញាធរឯករាជ្យ និងមានសមត្ថភាព ដោយគោរពទាំងស្រុងចំពោះគោលការណ៍រក្សាការសំងាត់។ វិធានការការពារត្រូវតែគិតគូរជាពិសេសអំពីហានិភ័យនៃការសងសឹក ។

២. ជនជាប់ឃុំស្ត្រីដែលបានទទួលរងនូវការបំពារបំពានលើផ្លូវភេទ ហើយជាពិសេស ស្ត្រីដែលមានផ្ទៃពោះដោយសារអំពើនោះ ត្រូវទទួលការណែនាំ និងការប្រឹក្សាយោបល់ សមស្របផ្នែកវេជ្ជសាស្ត្រ ហើយត្រូវផ្តល់ឲ្យពួកគាត់នូវការគាំទ្រ ការគាំពារសុខភាពខាងផ្លូវកាយ និងផ្លូវចិត្តតាមការចាំបាច់ ព្រមទាំងជំនួយផ្នែកច្បាប់ ។

៣.អធិការ ក្រុមប្រឹក្សា ទស្សនកិច្ច ឬក្រុមប្រឹក្សាត្រួតពិនិត្យ ឬគណៈគ្រប់គ្រង ត្រូវបញ្ចូលសមាជិកជាស្ត្រី ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការឃុំខ្លួន និងការគ្រប់គ្រងជនជាប់ឃុំស្ត្រី ។

## ៨. ការទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ

*[ វិធានបំពេញ ៣៧ -៣៩ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ២៦*

ការទំនាក់ទំនងរបស់ជនជាប់ឃុំស្ត្រីជាមួយក្រុមគ្រួសារ រាប់ទាំងកូនរបស់ពួកគាត់ អ្នកអាណាព្យាបាលរបស់កូនគាត់ និងអ្នកតំណាងស្របច្បាប់ ត្រូវបានជំរុញលើកទឹកចិត្ត និងជួយសម្រួលតាមគ្រប់មធ្យោបាយសមហេតុផល។ ប្រសិនជាអាច វិធានការផ្សេងៗ ត្រូវតែបានចាត់ឡើងដើម្បីរក្សាតុល្យភាពលើការខូចប្រយោជន៍ស្ត្រីដែលបានជាប់ឃុំនៅក្នុងស្ថាប័នទាំងឡាយដែលស្ថិតនៅឆ្ងាយពីលំនៅដ្ឋានរបស់ខ្លួន។

*វិធាន ២៧*

ប្រសិនជាអនុញ្ញាតឲ្យសហាព័ន្ធ(ការរួមសង្វាសជាមួយប្តី ប្រពន្ធ)សួរសុខទុក្ខ ជនជាប់ឃុំស្ត្រី ត្រូវតែអាចប្រើប្រាស់សិទ្ធិនេះ ដោយគោលការណ៍ស្មើភាពគ្នាជាមួយបុរស។

*វិធាន ២៨*

រាល់ការសួរសុខទុក្ខដែលទាក់ទងនឹងកូន ត្រូវតែបានធ្វើឡើងក្នុងបរិយាកាសមួយដែលនាំឲ្យមានបទពិសោធទស្សនកិច្ចមួយដែលវិជ្ជមាន រាប់បញ្ចូលទាំងអាកប្បកិរិយារបស់មន្ត្រី ហើយត្រូវអនុញ្ញាតឲ្យមានទំនាក់ទំនងមួយដែលបើកចំហររវាងម្តាយនិងកូន។ ការសួរសុខទុក្ខដោយផ្ទាល់ដែលមានរយៈពេលវែងជាមួយកូន គួរតែបានជំរុញលើកទឹកចិត្ត ប្រសិនជាអាចធ្វើបាន ។

## ៩. ការបណ្តុះបណ្តាល និងបុគ្គលិកស្ថាប័ន

*[ វិធានបំពេញ ៤៦ - ៥៥ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ២៩*

ការកសាងសមត្ថភាពដល់បុគ្គលិកដែលបំរើការក្នុងពន្ធនាគារស្ត្រី ត្រូវតែផ្តល់លទ្ធភាពឲ្យពួកគេដើម្បីដោះស្រាយសេចក្តីតម្រូវពិសេសផ្នែកសមាហរណកម្មសង្គមរបស់ជនជាប់ឃុំស្ត្រី និងគ្រប់គ្រងសុវត្ថិភាព និងសេវាស្តារនីតិសម្បទា។ វិធានការកសាងសមត្ថភាពសំរាប់បុគ្គលិកស្ត្រី ត្រូវរាប់បញ្ចូលផងដែរនូវការទទួលបានមុខតំណែងខ្ពស់ៗ ដែលមានការទទួលខុសត្រូវលើកិច្ចការសំខាន់ៗ សំរាប់ការបង្កើតនូវគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រង និងការគាំពារជនជាប់ឃុំស្ត្រី ។

*វិធាន ៣០*

ត្រូវមានការប្តេជ្ញាចិត្តមួយច្បាស់លាស់ និងប្រកបដោយចិរភាពនៅកំរិតថ្នាក់ដឹកនាំក្នុងការគ្រប់គ្រងពន្ធនាគារ ដើម្បីបង្ការ និងដោះស្រាយការរើសអើងខាងយ៉េនឌ័រប្រឆាំងនឹងបុគ្គលិកភេទស្ត្រី ។

*វិធាន ៣១*

ត្រូវបង្កើត និងអនុវត្តន៍គោលនយោបាយ និងបទបញ្ជាច្បាស់លាស់ស្តីពីក្រមសីលធម៌របស់បុគ្គលិកពន្ធនាគារ ក្នុងគោលដៅការពារជាអតិបរមាដល់ជនជាប់ឃុំស្ត្រី ពីអំពើហឹង្សាលើរូបកាយ ឬពាក្យសំដីផ្អែកលើមូលហេតុយ៉េនឌ័រ ការរំលោភបំពាន ការយាយីផ្លូវភេទ ។

*វិធាន ៣២*

បុគ្គលិកពន្ធនាគារស្ត្រី ត្រូវទទួលការបណ្តុះបណ្តាលស្មើភាពគ្នាជាមួយបុគ្គលិកពន្ធនាគារបុរស ហើយគ្រប់បុគ្គលិកដែលពាក់ព័ន្ធនឹងការគ្រប់គ្រងពន្ធនាគាររបស់ស្ត្រី ត្រូវទទួលការបណ្តុះបណ្តាលអំពីវេយិតភាពយេនឌ័រ និងការហាមប្រាមការរើសអើង និងការយាយីផ្លូវភេទ ។

*វិធាន ៣៣*

១. គ្រប់បុគ្គលិកទាំងអស់ដែលបានចាត់តាំងឲ្យធ្វើការជាមួយជនជាប់ឃុំស្ត្រី ត្រូវទទួលការបណ្តុះបណ្តាលអំពីសេចក្តីត្រូវការជាក់លាក់ខាងយ៉េនឌ័រ និងសិទ្ធិមនុស្សរបស់ជនជាប់ឃុំស្ត្រី ។

២. ត្រូវផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់បុគ្គលិកពន្ធនាគារដែលបំរើការក្នុងពន្ធនាគារស្ត្រី ស្តីពីបញ្ហាសំខាន់ៗដែលទាក់ទងដល់សុខភាពស្ត្រី បន្ថែមពីបច្ចេកទេសសង្គ្រោះបឋម និងវិជ្ជាពេទ្យជាមូលដ្ឋាន។

៣. បើសិនបើមានការអនុញ្ញាតឲ្យកូនរស់នៅជាមួយម្តាយក្នុងពន្ធនាគារ ត្រូវផ្តល់ផងដែរនូវការអប់រំ ផ្សព្វផ្សាយដល់បុគ្គលិកពន្ធនាគារ នូវការយល់ដឹងអំពីការរីកលូតលាស់របស់កុមារ និងការបណ្តុះបណ្តាលជាមូលដ្ឋានអំពីកិច្ចគាំពារសុខភាពរបស់កុមារ ដើម្បីឲ្យបុគ្គលិកទាំងនោះឆ្លើយតបសមស្រប និងទាន់ពេលវេលាចំពោះសេចក្តីត្រូវការ និងការសង្គ្រោះបន្ទាន់ ។

*វិធាន ៣៤*

១. កម្មវិធីកសាងសមត្ថភាពស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ នឹងត្រូវបានបញ្ចូលជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលទៀងទាត់របស់បុគ្គលិកពន្ធនាគារ ។ បន្ថែមពីលើការគាំពារ ការគាំទ្រ ការបង្ការ និងការព្យាបាលមេរោគអេដស៍/ជម្ងឺអេដស៍ បញ្ហាទាំងឡាយ ដូចជាយ៉េនឌ័រ និងសិទ្ធិមនុស្សដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើមេរោគអេដស៍/ជម្ងឺអេដស៍ ការគិតមិនល្អរលើពួកគាត់ និងការរើសអើងក៏ត្រូវបញ្ចូលជាផ្នែក មួយដែរនៃកម្មវិធីសិក្សា។

*វិធាន ៣៥*

បុគ្គលិកពន្ធនាគារត្រូវតែបានទទួលការបណ្តុះបណ្តាល ដើម្បីពិនិត្យមើលអំពីសេចក្តីត្រូវការ ការគាំពារផ្នែកសុខភាពផ្លូវចិត្តនិងហានិភ័យនៃគ្រោះថ្នាក់មកលើខ្លួន និងការធ្វើអត្តឃាតនៅក្នុងចំណោមជនជាប់ឃុំស្ត្រី ដើម្បីផ្តល់ការជួយឧបត្ថម្ភតាមរយៈការគាំទ្រ និងការបញ្ជូនករណីរឿងដូចនេះទៅអ្នកឯកទេស ។

## ១០. ជនជាប់ឃុំស្ត្រីជាអនីតិជន

*វិធាន ៣៦*

អាជ្ញាធរពន្ធនាគារត្រូវបង្កើតវិធានការផ្សេងៗ ដើម្បីបំពេញសេចក្តីត្រូវការខាងការការពារ របស់ជនជាប់ឃុំស្ត្រីជាអនីតិជន។

*វិធាន ៣៧*

ជនជាប់ឃុំស្ត្រីជាអនីតិជន ត្រូវមានសិទ្ធិស្មើគ្នាក្នុងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលមានសំរាប់ជនជាប់ឃុំអនីតិជនជាបុរស ។

*វិធាន ៣៨*

ជនជាប់ឃុំស្ត្រីជាអនីតិជន ត្រូវមានសិទ្ធិទទួលបានសេវា និងកម្មវិធីជាក់លាក់តាមអាយុ និង យ៉េនឌ័រជាអាទិ៍ ការពិគ្រោះយោបល់ទាក់ទងនឹងអំពើហឹង្សា ឬការរំលោភផ្លូវភេទ ។ ពួកគាត់ត្រូវទទួលការអប់រំអំពីការថែរក្សាសុខភាព និងទទួលការពិនិត្យព្យាបាលជាទៀងទាត់ពីគ្រូពេទ្យរោគស្ត្រី ដូចគ្នាផងដែរទៅនឹងជនជាប់ឃុំជានីតិជន។

*វិធាន ៣៩*

ជនជាប់ឃុំស្ត្រីជាអនីតិជនដែលមានផ្ទៃពោះ ត្រូវទទួលបានការគាំទ្រ និងកិច្ចគាំពារផ្នែកវេជ្ជសាស្ត្រដែលលក្ខណៈសមមូលទៅនឹងសេវាទាំងឡាយដែលបានផ្តល់ឲ្យជនជាប់ឃុំស្ត្រីជានីតិជន។ សុខភាពរបស់ពួកគាត់ ត្រូវបានពិនិត្យដោយអ្នកឯកទេសខាងវេជ្ជសាស្ត្រ ដោយគិតអំពីការដែលពួកគាត់អាចប្រឈមនឹងហានិភ័យច្រើនជាងនេះ លើការលំបាកខាងសុខភាពនៅក្នុងអំឡុងពេលមានផ្ទៃពោះ ដោយសារតែអាយុរបស់ពួកគាត់ ។

## II . វិធានដែលអនុវត្តចំពោះជំពូកពិសេស

## ក. ជនជាប់ឃុំដែលកំពុងជាប់ទោស

## I . ការធ្វើចំណាត់ថ្នាក់ជនជាប់ឃុំ និងឯកត្តភាវូបនីយ៍កម្ម

*[ វិធានបំពេញ ៦៧ - ៦៩ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ៤០*

អគ្គនាយកដ្ឋានពន្ធនាគារ ត្រូវបង្កើត និងអនុវត្តន៍វិធីសាស្ត្រនៃការធ្វើចំណាត់ថ្នាក់ ដែលដោះស្រាយកាលៈទេសៈ និងសេចក្តីត្រូវការជាក់លាក់ខាងយេនឌ័ររបស់ជនជាប់ឃុំស្ត្រី ដើម្បីធានាឲ្យមានការអនុវត្ត និងធ្វើផែនការ មានលក្ខណៈជាឯកត្តបុគ្គល និងសមរម្យ ឈានទៅរកការស្តារនីតិសម្បទា ការគ្រប់គ្រង និងការធ្វើសមាហរណកម្មឡើងវិញ ទៅក្នុងសង្គមមុនកាលកំណត់។

*វិធាន ៤១*

ការវាយតំលៃអំពីហានិភ័យវេយិតភាពយេឌ័រ និងការធ្វើចំណាត់ថ្នាក់ជនជាប់ឃុំត្រូវ ៖

(ក) គិតគូរអំពីហានិភ័យទូទៅនៅកំរិតទាបជាងនេះ ដែលបានបង្កឡើងដោយជនជាប់ឃុំស្ត្រីដល់ជនជាប់ឃុំដទៃទៀត ក៏ដូចជាផលប៉ះពាល់គ្រោះថ្នាក់ជាពិសេសដែលវិធានការសន្តិសុខកំរិតខ្ពស់ និងកំរិតកើនឡើងនៃការដាក់ឲ្យនៅដាច់ដោយឡែក ដែលអាចកើតមានទៅលើជនជាប់ឃុំស្ត្រី ។

(ខ) ផ្តល់លទ្ធភាពដែលអាចមានការគិតគូដល់ព័ត៌មានសំខាន់ៗ អំពីសវតារបស់ស្ត្រី ដូចជាអំពើហឹង្សាដែលពួកគាត់បានទទួលរង ប្រវត្តិពិការភាពខាងប្រាជ្ញាស្មារតីនិងការប្រើប្រាស់សារធាតុបំពានដែលបានហាមឃាត់(ការបំពានលើសារធាតុញៀន) ក៏ដូចជាការទទួលខុសត្រូវរបស់មាតាបិតា និងការថែរក្សាផ្សេងទៀតក្នុងការបីបាច់ថែរក្សាកូន សំរាប់ធ្វើផែនការកាត់ទោស និងការបញ្ជូនឬផ្ទេរ។

(គ) ធានាថាផែនការកាត់ទោសរបស់ស្ត្រី ដាក់បញ្ចូលនូវកម្មវិធី និងសេវាស្តារនីតិសម្បទាដែលស្របនឹងសេចក្តីត្រូវការជាក់លាក់ខាងយេនឌ័ររបស់ពួកគាត់ ។

(ឃ) ធានាថា ជនជាប់ឃុំស្រីទាំងឡាយណាដែលត្រូវការការគាំពារសុខភាពផ្លូវចិត្ត ត្រូវបានឲ្យស្នាក់នៅក្នុងបន្ទប់ដែលមិនមានការរិតបណ្តឹង និងក្នុងកំរិតសន្តិសុខទាបបំផុត តាមដែលអាចធ្វើបានហើយត្រូវបានគេប្រព្រឹត្តមកលើខ្លួនប្រកបដោយភាពត្រឹមត្រូវ ច្រើនជាងការដាក់ពួកគាត់ឲ្យនៅក្នុងកន្លែងដែលមានកំរិតសន្តិសុខខ្ពស់តែឯកឯង ដោយសារបញ្ហាសុខភាពផ្លូវចិត្តរបស់ពួកគាត់។

**២. របបពន្ធនាគារ**

*[ វិធានបំពេញ ៦៥ ៦៦ និង៧០ ដល់ ៨១ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ៤២*

១. ជនជាប់ឃុំស្ត្រីគ្រប់រូប ត្រូវទទួលបានអត្ថប្រយោជន៍ពីកម្មវិធីសកម្មភាពមួយទូលំទូលាយ និងមានតុល្យភាព ដែលគិតគូរអំពីសេចក្តីត្រូវការសមស្របខាងយេនឌ័រ ។

២. របបនៃពន្ធនាគារ ត្រូវឲ្យមានលក្ខណៈបត់បែនគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ស្ត្រីមានគត៌ ស្ត្រីដែលបំបៅកូន និងស្ត្រីដែលមានកូននៅជាមួយ។ ការរៀបចំ ឬកន្លែងថែរក្សាកុមារ ត្រូវបានផ្តល់អោយមានក្នុងពន្ធនាគារ ដើម្បីអាចឲ្យជនជាប់ឃុំស្ត្រីបានចូលរួមក្នុងសកម្មភាពពន្ធនាគារ ។

៣. ការខិតខំជាពិសេសមួយចំនួន ត្រូវបានធ្វើឡើងដើម្បីផ្តល់កម្មវិធីសមស្របសំរាប់ស្ត្រីដែលមានគត៌ ស្ត្រីដែលបំបៅកូន និងស្ត្រីដែលមានកូននៅជាមួយ។

៤. ការខិតខំជាពិសេសចំនួន ត្រូវបានធ្វើឡើងដើម្បីផ្តល់សេវាសមស្របសំរាប់ជនជាប់ឃុំស្ត្រី ដែលមានសេចក្តីត្រូវការគាំទ្រខាងផ្លូវចិត្ត ជាពិសេសជនជាប់ឃុំស្ត្រីទាំងឡាយដែលបាន ទទួលរងការរំលោភបំពានផ្លូវភេទ ផ្លូវកាយ ឬផ្លូវចិត្ត ។

**ទំនាក់ទំនងសង្គម និងកិច្ចគាំពារនៅពេលក្រោយ**

*[ វិធានបំពេញ ៧៩ - ៨១ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រង ជនជាប់ឃុំ]*

*វិធាន ៤៣*

អាជ្ញាធរពន្ធនាគារទាំងអស់ ត្រូវជំរុញលើកទឹកចិត្ត ហើយប្រសិនជាអាចធ្វើបាន ត្រូវជួយសម្រួលផងដែរដល់ការសួរសុខទុក្ខជនជាប់ឃុំស្ត្រី ដូចជាសេចក្តីត្រូវការជាមុនដែលសំខាន់ក្នុងការធានាដល់ សុខមាលភាពផ្លូវចិត្ត និងការធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ ។

*វិធាន ៤៤*

ពាក់ព័ន្ធបទពិសោធន៍នៃភាពវិសមាមាត្ររបស់ជនជាប់ឃុំស្ត្រី ចំពោះអំពើហិង្សាក្នុងគ្រួសារ ពួកគាត់ត្រូវបានផ្តល់ការពិគ្រោះយោបល់ ថាតើអ្នកណាអាចរាប់ថាជាសមាជិកគ្រួសារដែលអាចអនុញ្ញាតឲ្យចូលសួរសុខទុក្ខពួកគាត់បាន ។

*វិធាន ៤៥*

អាជ្ញាធរពន្ធនាគារទាំងអស់ ត្រូវប្រើជំរើសផ្សេងៗ មានដូចជា ការឈប់សំរាកទៅលេងស្រុក កំណើត ពន្ធនាគារបើកទូលាយ ការឃុំខ្លួនពាក់កណ្តាលពេលវេលា សេវានិងកម្មវិធីនៅមូលដ្ឋានសហគមន៍ ក្នុងកំរិតអតិបរមាដែលអាចធ្វើបាន សំរាប់ជនជាប់ឃុំស្ត្រី ដើម្បីសម្រួលការផ្លាស់ប្តូររបស់ពួកគាត់ពីពន្ធនាគារ ទៅមានសេរីភាពវិញ ក្នុងការកាត់បន្ថយការគិតមិនល្អរលើពួកគាត់ និងបង្កើតឡើងវិញនូវទំនាក់ទំនងរបស់ពួកគាត់ជាមួយក្រុមគ្រួសារគាត់នៅដំណាក់កាលដំបូងបំផុតតាមដែលអាចធ្វើបាន ។

*វិធាន ៤៦*

អាជ្ញាធរពន្ធនាគារទាំងអស់ដោយសហការគ្នា ជាមួយនឹងការសាកល្បង និងឬ សេវាសុខមាលភាពសង្គម ក្រុមសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំ និងអនុវត្តកម្មវិធីទូលំទូលាយក្នុងការធ្វើសមាហរណកម្ម មុនពេលនិងក្រោយពេលដោះលែងពួកគាត់ ដែលគិតគូរអំពីសេចក្តីត្រូវការជាក់លាក់របស់ស្ត្រីលើផ្នែកយេនឌ័រ ។

*វិធាន ៤៧*

ការជួយឧបត្ថម្ភបន្ថែមបន្ទាប់ពីការដោះលែងឲ្យមានសេរីភាព ត្រូវបានផ្តល់ជូនជនជាប់ឃុំស្ត្រីណាដែលបានដោះលែង ត្រូវការការជួយឧបត្ថម្ភខាងផ្លូវចិត្ត វេជ្ជសាស្ត្រ ច្បាប់ និងជំនួយមានប្រយោជន៍ ដើម្បីធានាការធ្វើសមាហរណកម្មពួកគាត់ក្នុងសង្គមប្រកបដោយជោគជ័យ ដោយសហការជាមួយសេវាផ្សេងៗនៅក្នុងសហគមន៍ ។

## ៣. ស្ត្រីមានគត៌ ម្តាយបំបៅកូនដោយទឹកដោះ និងម្តាយរស់នៅជាមួយកូនក្នុងពន្ធនាគារ

*[ វិធានបំពេញ ២៣ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រង អ្នកទោស]*

*វិធាន ៤៨*

១. ជនជាប់ឃុំស្ត្រីមានគត៌ និងជនជាប់ឃុំស្ត្រីមានកូននៅជាមួយ ត្រូវទទួលការណែនាំអំពី សុខភាព និងរបបអាហាររបស់ពួកគាត់ ក្រោមកម្មវិធីមួយដែលនឹងត្រូវបានរៀបចំតាក់តែងឡើង និងឃ្លាំមើលដោយអ្នកជំនាញសុខាភិបាលមួយរូប។ អាហារគ្រប់គ្រាន់និងទៀងពេលវេលា បរិស្ថានសុខភាព និងឱកាសធ្វើលំហាត់ប្រាណទៀងទាត់ នឹងត្រូវផ្តល់ជូនដោយឥតគិតថ្លៃដល់ស្ត្រី មានគត៌ ទារក កុមារ និងម្តាយដែលបំបៅដោះកូនដោយទឹកដោះ ។

២. ជនជាប់ឃុំស្ត្រី មិនត្រូវបានគេធ្វើឲ្យរាចិត្តក្នុងការបំបៅកូនដោយទឹកដោះឡើយ លុះត្រាតែពួកគាត់មានហេតុផលសុខភាពណាមួយ ដែលតម្រូវអោយគាត់មិនអាចបំបៅដោះបាន។

៣. សេចក្តីត្រូវការខាងអាហារូបត្ថម្ភ និងខាងវេជ្ជសាស្ត្ររបស់ជនជាប់ឃុំស្ត្រី ដែលទើបសំរាលកូន ប៉ុន្តែកូនរបស់ពួកគាត់មិននៅជាមួយគាត់ក្នុងពន្ធនាគារ ត្រូវបានបញ្ចូលនៅក្នុងកម្មវិធីព្យាបាល ។

*វិធាន ៤៩*

ការសំរេចអនុញ្ញាតឲ្យកុមារស្នាក់នៅជាមួយម្តាយរបស់ខ្លួនក្នុងពន្ធនាគារ ត្រូវផ្អែកលើឧត្តមប្រយោជន៍របស់កុមារ។ កុមារនៅក្នុងពន្ធនាគារជាមួយម្តាយ មិនត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូចជនជាប់ ឃុំឡើយ។

*វិធាន ៥០*

ជនជាប់ឃុំស្ត្រីដែលមានកូនរស់នៅជាមួយក្នុងពន្ធនាគារ ត្រូវបានផ្តល់ឱកាសច្រើនជាអតិបរមា តាមដែលអាចធ្វើបាន ដើម្បីឲ្យគាត់មានពេលវេលសំរាប់មើលថែទាំកូន ។

*វិធាន ៥១*

១. កុមារដែលកំពុងរស់នៅជាមួយម្តាយនៅក្នុងពន្ធនាគារ ត្រូវបានផ្តល់នូវសេវាគាំពារ សុខភាពប្រចាំថ្ងៃ ហើយការរីកលូតលាស់របស់ពួកគេត្រូវបានតាមឃ្លាំមើលដោយអ្នកឯកទេស ដោយសហការជាមួយសេវាសុខភាពសហគមន៍ ។

២. បរិស្ថានដែលបានផ្តល់សំរាប់ការចិញ្ចឹមបីបាច់ អប់រំកូនដូចនេះ ត្រូវមានសភាពដូចទៅកុមារដែលនៅខាងក្រៅពន្ធនាគារ តាមដែលអាចធ្វើទៅបាន។

*វិធាន ៥២*

១. ការសំរេចថាតើពេលណាទើបអាចបំបែកកូនចេញម្តាយរបស់ខ្លួននោះ ត្រូវតែផ្អែកលើការវាយតំលៃលើបុគ្គល និងលើឧត្តមប្រយោជន៍របស់កុមារនៅក្នុងវិសាលភាពនៃច្បាប់ជាតិដែលពាក់ព័ន្ធ ។

២. ការនាំយកកុមារចេញពីពន្ធនាគារ ត្រូវតែបានធ្វើឡើងក្នុងលក្ខណៈវេទយិតភាព តែល្អិតណាដែលមានការរៀបចំគាំពារក្នុងជំរើសផ្សេងៗសំរាប់កុមារ ត្រូវបានគេកំណត់ និងក្នុងករណីនៃជនជាប់ឃុំជាតិបរទេស ដោយមានការពិគ្រោះយោបល់ជាមួយមន្ត្រីស្ថានកុងស៊ុលរបស់ពួកគាត់ ។

៣. បន្ទាប់ពីការបំបែកកុមារចេញពីម្តាយ និងបានដាក់ឲ្យរស់នៅជាមួយក្រុមគ្រួសារ ឬសាច់ញាតិ ឬស្ថិតក្នុងកិច្ចគាំពារជំរើសផ្សេងទៀត ជនជាប់ឃុំស្ត្រីត្រូវបានផ្តល់ឱកាស និងសេវាជាអតិបរមាតាមដែលអាចធ្វើបាន ដើម្បីជួបជាមួយកូនរបស់ខ្លួន នៅពេលដែលធ្វើដូចនេះជាឧត្តមប្រយោជន៍របស់កុមារហើយ ប្រសិនមិនប៉ះពាល់ដល់សុវត្ថិភាពសាធារណៈទេនោះ ។

**៤. ជនជាប់ឃុំបរទេស**

*[ វិធានបំពេញ ៣៨ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ៥៣*

១. ប្រសិនជាមានកិច្ចព្រមព្រៀងពាក់ព័ន្ធទ្វេភាគី ឬពហុភាគី ការផ្ទេរជនជាប់ឃុំបរទេសជាស្ត្រីពីប្រទេសមិនមែនដើមកំណើតទៅកាន់ប្រទេសខ្លួនវិញ គេត្រូវតែធ្វើការពិចារណាឲ្យបានឆាប់ តាមដែលអាចធ្វើបាន នៅក្នុងអំឡុងពេលពួកគាត់កំពុងជាប់ពន្ធនាគារ ដោយមានការដាក់ពាក្យ ឬផ្តល់ព័ត៌មានយល់ព្រមពីជនជាប់ឃុំបរទេសជាស្ត្រីដែលពាក់ព័ន្ធ ។

២. ប្រសិនជាមានកុមាររស់នៅជាជនជាប់ឃុំបរទេសជាស្ត្រី ដែលពន្ធនាគារនោះមិនមែនជាប្រទេសដើមកំណើតខ្លួន កុមារដែលត្រូវបាននាំចេញពីពន្ធនាគារនោះ គេត្រូវពិចារណាអំពីការរៀបចំបញ្ជូនកុមារនោះទៅប្រទេសកំណើតរបស់ខ្លួន ដោយគិតគូរអំពីឧត្តមប្រយោជន៍របស់កុមារ និងដោយមានការពិគ្រោះយោបល់ជាមួយស្ត្រីជាម្តាយ ។

**៥. ជនភាគតិច និង ជនជាតិដើមភាគតិច**

*វិធាន ៥៤*

អាជ្ញាធរពន្ធនាគារត្រូវទទួលស្គាល់ថា ជនជាប់ឃុំស្ត្រីដែលមានប្រវត្តិសវតាវប្បធម៌ និងសាសនាផ្សេងៗ មានសេចក្តីត្រូវការរៀងខ្លួន និងអាចប្រឈមទៅនឹងរូបភាពទាំងឡាយនៃការរើសអើងក្នុងការទទួលបានកម្មវិធី និងសេវាទាក់ទងនឹងវប្បធម៌និងយ៉េនឌ័រ។ ដូចនេះ អាជ្ញាធរពន្ធនាគារត្រូវផ្តល់សេវា និងកម្មវិធី

ទូលំទូលាយឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនេះ ដោយមានការពិគ្រោះយោបល់ជាមួយជនជាប់ឃុំស្ត្រីផ្ទាល់ និងជាមួយក្រុមទាំងឡាយដែលពាក់ព័ន្ធ ។

*វិធាន ៥៥*

សេវា មុនពេល និងក្រោយពេលដោះលែងនឹងត្រូវបានពិនិត្យឡើងវិញ ដើម្បីធ្វើឲ្យប្រាកដថាសេវាទាំងនោះមានលក្ខណៈសមស្រប អាចឲ្យជនជាប់ឃុំស្ត្រីជនជាតិដើមភាគតិចទទួលបាន និងបានដល់ជនជាប់ឃុំស្ត្រីមកពីក្រុមជាតិពន្ធ និងជាតិសាសន៍ផ្សេងៗ ដោយមានការពិគ្រោះយោបល់ជាមួយក្រុមទាំងឡាយ ដែលពាក់ព័ន្ធ ។

## ខ. ជនជាប់ឃុំស្ត្រីស្ថិតក្នុងការចាប់ខ្លួន ឬកំពុងរង់ចាំសវនាការ

*[ វិធានបំពេញ ៨៤- ៩៣ នៃបទបញ្ញត្តិជាបទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងជនជាប់ឃុំ]*

*វិធាន ៥៦*

ហានិភ័យដោយឡែកនៃការរំលោភបំពាន ដែលស្ត្រីប្រឈមមុខក្នុងដំណាក់កាលនៃការឃុំខ្លួនមុនសវនាការ ត្រូវតែមានការទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ ដែលត្រូវអនុម័តវិធានការសមស្របមួយចំនួនក្នុងគោលនយោបាយ និងការអនុវត្ត ដើម្បីធានាសុវត្ថិភាពរបស់ស្ត្រីទាំងអស់នោះ នៅក្នុងដំណាក់កាលនេះ (សូមមើលផងដែរ វិធាន ៥៨ ខាងក្រោម ដែលនិយាយអំពីជំរើសផ្សេងៗជំនួសឲ្យការឃុំខ្លួនមុនសវនាការ។)

## III. វិធានការមិនឃុំខ្លួន

*វិធាន ៥៧*

បទបញ្ញត្តិនៃវិធានតូក្យូ ត្រូវណែនាំពីការអភិវឌ្ឍ និងការអនុវត្តការឆ្លើយតបសមស្របចំពោះជនល្មើសជាស្ត្រី ជំរើសជាក់លាក់ខាងយេនឌ័រសំរាប់វិធានការបង្វែរ និងជំរើសមុនពេលសវនាការ និងការ

កាត់ទោសត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធច្បាប់នៃរដ្ឋសមាជិក ដោយគិតគូរអំពីប្រវត្តិនៃការធ្វើឲ្យរងគ្រោះនៃជនល្មើសជាស្ត្រីជាច្រើន និងការទទួលខុសត្រូវខាងការថែទាំរបស់ពួកគេ។

*វិធាន ៥៨*

ដោយគិតគូរអំពីបទបញ្ញត្តិនៃវិធាន ២.៣ នៃវិធានតូក្យូ ជនល្មើសជាស្ត្រី មិនត្រូវបានគេដាក់បំបែកចេញក្រុមគ្រួសារ និងសហគមន៍របស់ពួកគាត់ ដោយមិនបានគិតគូរពិចារណាត្រឹមត្រូវអំពីសវតាជាតិ និងចំណងទាក់ទងរបស់គ្រួសារពួកគាត់ឡើយ។ ជំរើសផ្សេងនៃការគ្រប់គ្រងស្ត្រី ដែលប្រព្រឹត្តល្មើសដូចជាវិធានការបង្វែរ និងជំរើសមុនពេលសវនាការ និងការកាត់ទោស ត្រូវបានអនុវត្តតាមការគួរ និងតាមដែលអាចធ្វើបាន។

*វិធាន ៥៩*

ជាទូទៅ មធ្យោបាយការពារមិនឃុំខ្លួន ឧទាហរណ៍ ដូចជានៅក្នុងទីជំរកដែលគ្រប់គ្រងដោយស្ថាប័នឯករាជ្យ អង្គការមិនមែនរដ្ឋាភិបាល ឬសេវាសហគមន៍ផ្សេងទៀត ត្រូវបានប្រើប្រាស់ដើម្បី ការពារស្ត្រីដែលត្រូវការការការពារបែបនេះ។ វិធានការបណ្តោះអាសន្នមួយចំនួនទាក់ទងនឹងការឃុំគ្រងដើម្បី ការពារស្ត្រីណាមួយ ត្រូវបានអនុវត្តតែនៅពេលដែលចាំបាច់ និងមានការស្នើសុំច្បាស់លាស់ពីស្ត្រីជាសាម៉ីខ្លួន ហើយគ្រប់ករណីទាំងអស់ត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត។ វិធានការការពារទាំងនេះ មិនត្រូវបន្តអនុវត្តផ្ទុយទៅនឹងឆន្ទៈរបស់ស្ត្រីជាសាម៉ីខ្លួនឡើយ ។

*វិធាន ៦០*

ធនធានសមស្រប ត្រូវបានរៀបចំឲ្យមាន សំរាប់បង្កើតជំរើសសមស្របសំរាប់ជនល្មើសជាស្ត្រី ដើម្បីបញ្ចូលវិធានការជំនួសការឃុំខ្លួន ជាមួយនឹងការធ្វើអន្តរាគមន៍ ដើម្បីដោះស្រាយបញ្ហារួមភាគច្រើន ដែលភ្ជាប់ទំនាក់ទំនងរបស់ស្ត្រីជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ការនេះ អាចរាប់បញ្ចូលនូវវគ្គសិក្សាអំពីវិធីព្យាបាល និងសេវាប្រឹក្សាយោបល់សំរាប់ជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ ការពិនិត្យព្យាបាលស្រមស្របសំរាប់ស្ត្រី ដែលមានពិការភាពខាងបញ្ញាស្មារតី និងកម្មវិធីអប់រំ និងបណ្តុះបណ្តាលដើម្បីពង្រឹងលទ្ធភាព ការងារនិងមុខរបរ ។ កម្មវិធីទាំងនេះ ត្រូវគិតគូរអំពីសេចក្តីត្រូវការសេវាគាំពារស្ត្រីនិងកុមារ ។

*វិធាន ៦១*

នៅពេលកាត់ទោសជនល្មើសជាស្ត្រី តុលាការត្រូវមានអំណាចពិចារណាលើស្ថានសម្រាល ដូចជាការមិនធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ចរិតលក្ខណៈ និងភាពមិន ធ្ងន់ធ្ងរពាក់ព័ន្ធនឹងការប្រព្រឹត្ត

បទល្មើសព្រហ្មទណ្ឌ ដោយគិតដល់តួនាទីរបស់ស្ត្រីក្នុងការថែរក្សាកូន និងតាមបែបផែន សវតាដទៃផ្សេងៗទៀត។

*វិធាន ៦២*

ការផ្តល់ឲ្យមានកម្មវិធីយល់ដឹងអំពីយ៉េនឌ័រ ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាផ្លូវចិត្ត កម្មវិធីព្យាបាលការប្រើប្រាស់សារធាតុញៀនសំរាប់ស្ត្រី តែមួយមុខប៉ុណ្ណោះនៅក្នុងសហគមន៍ និងសិទ្ធិទទួលបានកម្មវិធីដូចនេះត្រូវបានធ្វើឲ្យប្រសើរឡើង សំរាប់ការបង្ការបទល្មើស ក៏ដូចជា សំរាប់គោលបំណងបង្វែរ និងជំរើសផ្សេងពីការដាក់ពន្ធនាគារ ។

## ១. ការរៀបចំចាត់ចែង ក្រោយពេលកាត់ទោស

*វិធាន ៦៣*

រាល់សំរេចទាក់ទងនឹងការដោះលែងមានលក្ខខណ្ឌ ត្រូវផ្តោតការគិតគូរអំពីតួនាទីរបស់ជនជាប់ឃុំស្ត្រីក្នុងការថែរក្សាកូន ក៏ដូចជាសេចក្តីត្រូវការពិសេសរបស់ពួកគាត់ក្នុងការធ្វើសមាហរណកម្មក្នុងសង្គម។

## ២. ស្ត្រីមានផ្ទៃពោះ និង ស្ត្រីមានកូនក្នុងបន្ទុក

*វិធាន ៦៤*

ការផ្តន្ទាទោសដោយមិនដាក់ពន្ធនាគារ សំរាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីមានកូនក្នុងបន្ទុក ត្រូវតែយកមកគិតគូរតាមការចាំបាច់ និងសមស្រប ដោយគិតគូអំពីការផ្តន្ទាទោសដាក់ពន្ធនាគារ ពេលដែលអំពើល្មើសនោះ មានចរិតលក្ខណៈធ្ងន់ធ្ងរ ឬហឹង្សា ឬស្ត្រីនោះអាចនឹង បន្តបង្កគ្រោះថ្នាក់ ហើយបន្ទាប់ពីបានគិតគូរអំពីឧត្តមប្រយោជន៍របស់កុមារ ទន្ទឹមនឹងនេះក៏ត្រូវ ធានាផ្តល់កិច្ចគាំពារឲ្យបានសមស្របដល់កុមារទាំងនោះផងដែរ ។

## ៣. ជនល្មើសស្ត្រីជាអនីតិជន

*វិធាន ៦៥*

ការដាក់កុមារមានទំនាស់នឹងច្បាប់ក្នុងគ្រឹះស្ថានមួយ ត្រូវតែជៀសវាងតាមដែលអាចធ្វើទៅបាន។ ភាពងាយរងគ្រោះដោយយ៉េនឌ័រនៃជនល្មើសស្ត្រីជាអនីតិជន ត្រូវតែគិតគូរនៅក្នុងការធ្វើការសំរេចផ្សេងៗ។

**៤. ជនជាតិបរទេស**

*វិធាន ៦៦*

កិច្ចខិតខំប្រឹងប្រែងជាអតិបរមា ត្រូវបានធ្វើឡើងដើម្បីផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជា-ជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន[ឈ] និង ពិធីសារស្តីពីការបង្ការការបង្ក្រាប និងការផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ បំពេញលើអនុសញ្ញានោះ[ណ] ដើម្បីអនុវត្តពេញលេញនូវបទបញ្ញត្តិនៃអនុញ្ញានេះ ក្នុងការផ្តល់កិច្ចការពារជាអតិបរមាដល់ជនរងគ្រោះដោយការជួញដូរមនុស្ស ដើម្បីកុំឲ្យស្ត្រីជនបរទេសជាច្រើនក្លាយជាជនរងគ្រោះជាលើកទីពីរទៀត ។

**I V. ការស្រាវជ្រាវ ការធ្វើផែនការ ការវាយតំលៃ និង ការលើកកំពស់ការយល់ដឹងជាសាធារណ**

**១. ការស្រាវជ្រាវ ការធ្វើផែនការ ការវាយតំលៃ**

*វិធាន ៦៧*

កិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើងដើម្បីរៀបចំ និងលើកកំពស់ការស្រាវជ្រាវជាទូទៅ និងតំរង់ទិសលទ្ធផលស្តីពីបទល្មើសដែលបានប្រព្រឹត្តដោយស្ត្រី ហេតុផលដែលជាគន្លឹះនៃការប្រឈមមុខរបស់ស្ត្រីជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ផលប៉ះពាល់ទៅលើស្ត្រីនៃការការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនិងការជាប់ពន្ធនាគារជាលើកទីពីរ ចរិតលក្ខណៈរបស់ជនល្មើសស្ត្រី ក៏ដូចជាកម្មវិធីផ្សេងៗដែលបានបង្កើតឡើងដើម្បីកាត់បន្ថយការប្រព្រឹត្តល្មើសជាថ្មីដោយស្ត្រី ជាមូលដ្ឋានសំរាប់ការធ្វើផែនការ ការបង្កើតកម្មវិធីនិងការធ្វើគោលនយោបាយប្រកបដោយប្រសិទ្ធិភាព ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការក្នុងការធ្វើសមាហរណកម្មជនល្មើសស្ត្រីទៅក្នុងសង្គមរបស់ពួកគេ ។

*វិធាន ៦៨*

---

[ឈ] អង្គការសហប្រជាជាតិ៖ កម្រងលិខិតុបករណ៍អន្តរជាតិ/ ភាគទី២២២៥ លេខ៣៩៥៧៤

[ណ] អង្គការសហប្រជាជាតិ៖ កម្រងលិខិតុបករណ៍អន្តរជាតិ/ ភាគទី២២៣៧ លេខ៣៩៥៧៤

កិច្ចខិតខំប្រឹងប្រែង នឹងត្រូវបានធ្វើឡើងដើម្បីរៀបចំ និងលើកកំពស់ការស្រាវជ្រាវអំពីចំនួនកុមារដែលប៉ះពាល់ដោយបញ្ហាប្រឈមនៃម្ដាយរបស់ខ្លួនជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងជាពិសេសការជាប់ពន្ធនាគារ និងផលប៉ះពាល់នៃបញ្ហានេះទៅលើកុមារ ដើម្បីចូលរួមចំណែកក្នុងការបង្កើតគោលនយោបាយ និងការបង្កើតកម្មវិធីផ្សេងៗ ដោយគិតគូរអំពីឧត្តមប្រយោជន៍របស់កុមារ ។

*វិធាន ៦៩*

កិច្ចខិតខំប្រឹងប្រែង នឹងត្រូវបានធ្វើឡើងដើម្បីពិនិត្យឡើងវិញ វាយតំលៃ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមកាលកំណត់នូវនិន្នាកា បញ្ហា និងកត្តាផ្សេងៗដែលទាក់ទងនឹងឥរិយាបទ ខុសឆ្គងរបស់ស្ត្រី និង ប្រសិទ្ធិភាពក្នុងការឆ្លើយតបទៅនឹងសេចក្ដីត្រូវការសំរាប់ការធ្វើសមាហរណកម្មស្ត្រីដែលប្រព្រឹត្តល្មើសទៅក្នុងសង្គម ក៏ដូចជាកូនរបស់ពួកគេ ដើម្បីកាត់បន្ថយការគិតមិនល្អរលើពួកគាត់ និងផលប៉ះពាល់អវិជ្ជមាននៃបញ្ហាប្រឈមរបស់ស្ត្រីទាំងនោះជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌទៅលើពួកគេ ។

## ២. ការផ្សព្វផ្សាយការយល់ដឹងជាសាធារណ ការចែករំលែកព័ត៌មាន និង ការបណ្ដុះបណ្ដាល

*វិធាន ៧០*

១. សារព័ត៌មាន និង សាធារណៈជន នឹងត្រូវបានជូនដំណឹងអំពីហេតុផលដែលស្ត្រីជាប់អន្ទាក់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងអំពីមធ្យោបាយមានប្រសិទ្ធិភាពបំផុត ក្នុងការឆ្លើយតបនឹងបញ្ហានេះ ដើម្បីអាចឲ្យស្ត្រីធ្វើសមាហរណកម្មទៅក្នុងសង្គម ដោយគិតគូរអំពីឧត្តមប្រយោជន៍របស់កូនពួកគាត់ ។

២. ការបោះពុម្ព និង ការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងឧទាហរណ៍នៃការអនុវត្តន៍ល្អ ត្រូវបង្កើតជាធាតុផ្សំដ៏ទូលំទូលាយសំរាប់គោលនយោបាយសំដៅបង្កើនលទ្ធផល និងភាពត្រឹមត្រូវយុត្តិធម៌ដល់ស្ត្រី និងកូនរបស់ពួកគាត់ ជាការឆ្លើយតបខាងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះជនល្មើសជាស្ត្រី ។

៣. សារព័ត៌មាន សាធារណៈជន និង បុគ្គលទាំងឡាយមានទំនួលខុសត្រូវខាងវិជ្ជាជីវៈក្នុងបញ្ហាទាំងឡាយទាក់ទងនឹងជនជាប់ឃុំ ជនល្មើសស្ត្រី នឹងត្រូវបានផ្ដល់ជាទៀងទាត់នូវ ព័ត៌មានជាអង្គហេតុអំពីបញ្ហាផ្សេងៗដែលគ្របដណ្ដប់ក្នុងវិធាន និងការអនុវត្តន៍វិធានទាំងនេះ។

៤. កម្មវិធីបណ្តុះបណ្តាលស្តី អំពីវិធាននេះ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវ នឹងត្រូវបានបង្កើត និងអនុវត្តសំរាប់មន្ត្រីពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីលើកកំពស់ការយល់ដឹងរបស់ពួកគេ និងឲ្យពួកគេយល់ដឹងអំពីបទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងវិធាននេះ ។

Thailand Institute of Justice
affiliated with the United Nations